**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្នើឲ្យឈប់ការប្រើប្រាស់តុលាការដើម្បីផ្តន្ទាទោសលើអ្នកហ៊ាននិយាយអំពីសិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ (ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១)៖ នៅថ្ងៃនេះ អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ* បានរិះគន់ប្រទេសកម្ពុជាយ៉ាងខ្លាំងក្នុងការ "ប្រើប្រាស់" ប្រព័ន្ធតុលាការជាមធ្យោបាយក្នុងកាត់បន្ថយវិសាលភាពសម្រាប់សកម្មភាពរបស់ពលរដ្ឋ និងអំពាវនាវឲ្យប្រទេសកម្ពុជាការពារសេរីភាពបញ្ចេញមតិ ក្រោយពីអ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយសរុប ១៥ នាក់ក្នុងសំណុំរឿងពីរផ្សេងគ្នាត្រូវបានតុលាការផ្តន្ទាទោស។

អ្នកជំនាញឯករាជ្យបានមានប្រសាសន៍ថា "យើងខ្ញុំព្រួយបារម្ភជាខ្លាំងអំពីសាលក្រមផ្តន្ទាទោសទាំងនេះ ដែលសរបញ្ជាក់ជាថ្មីម្តងទៀតនូវការធ្លាក់ចុះនៃលំហពលរដ្ឋ និងនយោបាយនៅកម្ពុជា ដែលមានលក្ខណៈជាប្រព័ន្ធ និងមានការរៀបចំច្បាស់លាស់។" "យើងខ្ញុំពិតជាភ្ញាក់ផ្អើលដែលថាតុលាការត្រូវបានប្រើប្រាស់ជាមធ្យោបាយជាថ្មីទៀតក្នុងបំបិទសំឡេងរិះគន់របស់អ្នកដែលហ៊ាននិយាយរិះគន់ រួមទាំងសកម្មភាពអហិង្សាដែលត្រូវបានការពារដោយសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។"

អ្នកជំនាញឯករាជ្យបានលើកឡើងពីបញ្ហានេះ បន្ទាប់ពីអ្នកការពារសិទ្ធិមនុស្សចំនួន ៧ នាក់ដែលជាសមាជិកខ្មែរថាវរៈ និងសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ដែលពួកគាត់ធ្វើយុទ្ធនាការដើម្បីសិទ្ធិមនុស្ស ការការពារបរិស្ថាន និងយុត្តិធម៌សង្គម ហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ២០ ខែ និងរងការពិន័យជាប្រាក់ ៥០០ ដុល្លារ ក្នុងម្នាក់ៗ ពីបទចោទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬបង្កភាពវឹកវរក្នុងសង្គម កាលពីថ្ងៃទី២៦ ខែតុលា។ សមាជិកគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សនយោបាយត្រូវបានតុលាការសម្រេចរំលាយ ចំនួន ៧ រូបក៏ត្រូវបានផ្តន្ទាទោសក្នុងបទចោទដូចគ្នាក្នុងសំណុំរឿងតែមួយនេះដែរ ដោយក្នុងនោះមាន ៤ រូបត្រូវបានផ្តន្ទាទោស*កំបាំងមុខ*។

នៅពេលដែលសាលក្រមផ្តន្ទាទោសនេះប្រកាស មានអ្នកការពារសិទ្ធិមនុស្សចំនួន ២៥ រូបកំពុងស្ថិតក្នុងពន្ធនាគារនៅប្រទេសកម្ពុជា ដែលជាចំនួនច្រើនបំផុតក្នុងរយៈពីរឆ្នាំនេះ។

អ្នកការពារសិទ្ធិមនុស្សរួមមាន៖ កញ្ញា ឈឿន ដារ៉ាវី, លោក ហ៊ុន វណ្ណៈ, ព្រះតេជគុណ កើត សារ៉ាយ, លោក ថា ឡាវី, កញ្ញា អេង ម៉ាឡៃ, លោក មួង សុភ័ក្រ្ត, និងលោក មាន ព្រហ្មមុនី ដែលត្រូវបានចាប់ខ្លួនពីកន្លែងផ្សេងៗគ្នាក្នុងខែសីហា និងខែកញ្ញា ឆ្នាំមុន។ កញ្ញា អេង ម៉ាឡៃ ត្រូវបានចាប់ខ្លួន បន្ទាប់ពីចាកចេញពីការិយាល័យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។

ពួកគាត់ត្រូវបានឃុំខ្លួនអស់រយៈពេល ១៣ ខែ ខណៈពេលរង់ចាំសវនាការ ដែលជាការរំលោភបំពានទាំងច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ។ អ្នកជំនាញឯករាជ្យបានរិះគន់លើការបដិសេធឲ្យនៅក្រៅឃុំចំពោះអ្នកការពារសិទ្ធិមនុស្សទាំងនេះផងដែរ។

នៅក្នុងសំណុំរឿងមួយផ្សេងទៀត នៅថ្ងៃទី១ ខែវិច្ឆិកា កុមារាអាយុ១៦ ឆ្នាំម្នាក់ត្រូវបានតុលាការផ្តន្ទាទោសពីបទចោទញុះញង់ និងប្រមាថមន្ត្រីរាជការសាធារណៈ ឲ្យទទួលទោសពន្ធនាគារ ៨ ខែ ដោយត្រូវស្ថិត

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរយៈពេល ២ ឆ្នាំបន្ថែមទៀត។ ក្មេងប្រុសរូបនេះត្រូវអនុវត្តទោសពន្ធនាគារចំនួន ៤ ខែ និង ១៥ ថ្ងៃ ហើយទោសនៅសល់ត្រូវបានព្យួរ ដូច្នេះគាត់គួរតែត្រូវបានដោះលែងឲ្យមានសេរីភាពវិញឆាប់ៗនេះ។ ឪពុករបស់ក្មេងប្រុសនេះគឺជាសកម្មជនគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំ ហើយម្ដាយគាត់គឺជាសមាជិក សកម្មនៃក្រុមស្ត្រីថ្ងៃសុក្រ ដែលក្រុមប្រមូលផ្ដុំដោយសមាជិកគ្រួសាររបស់សកម្មជនគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំ ហើយពួកគាត់តែងតែធ្វើការប្រមូលផ្ដុំប្រចាំសប្ដាហ៍ដើម្បីទាមទារឲ្យមានការដោះលែងសមាជិកគ្រួសារជាទីស្រឡាញ់របស់ពួកគាត់។

អ្នកជំនាញឯករាជ្យបានមានប្រសាសន៍លើការផ្ដន្ទាទោសក្មេងប្រុសរូបនេះថា “ការផ្ដន្ទាទោសលើអនីតិជនដែលមានបញ្ហាស្មារតីមិនប្រក្រតីដោយជំងឺអូទីស្សឹម គឺជារូបភាពដ៏អាក្រក់នៃយុទ្ធនាការជាបន្តបន្ទាប់របស់អាជ្ញាធរក្នុងការបំភិតបំភ័យ និងការប្រើហិង្សាប្រឆាំងនឹងសង្គមស៊ីវិល និងសកម្មជនបក្សជំទាស់ ព្រមទាំងសមាជិករបស់ក្រុមទាំងនេះ។

ពីរឆ្នាំកន្លងទៅ អ្នកជំនាញឯករាជ្យទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានសរសេរលិខិតជារឿយៗជូនចំពោះរដ្ឋមន្ត្រីក្រសួងការបរទេស ដើម្បីលើកឡើងពីក្ដីបារម្ភនានាអំពីការផ្ដន្ទាទោសលើអ្នកធ្វើកិច្ចការអំពីសិទ្ធិមនុស្ស។

ករណីទាំងនេះរួមទាំងការផ្ដន្ទាទោសលើមេដឹកនាំសហជីពដ៏លេចធ្លោ គឺលោក រ៉ុង ឈុន និងអ្នកគាំទ្រគាត់ ២ រូបគឺ កញ្ញា ស កនិកា និងលោក ទុន និមល កាលពីខែសីហា ឆ្នាំ២០២១ និងអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថាន ៣ រូបផ្សេងទៀតគឺ កញ្ញា ឡុង គន្ធា, កញ្ញា ភួន កែវរស្មី និង កញ្ញា ស៊ុន រដ្ឋា កាលពីខែឧសភាឆ្នាំ២០២១។ អ្នកជំនាញឯករាជ្យក៏បានលើកឡើងជំទាស់នឹងសកម្មភាពបែបហិង្សាលើបាតុករអហិង្សាក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២០ ផងដែរ។

ក្នុងខែតុលា ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តសេចក្ដីសម្រេចអំពីប្រទេសកម្ពុជា ដែលបានបង្ហាញនូវក្ដីបារម្ភធ្ងន់ធ្ងរអំពីការកាន់តែធ្លាក់ចុះនៃបរិយាកាសសិទ្ធិពលរដ្ឋ និងនយោបាយដោយសារតែការធ្វើទុក្ខបុកម្នេញតាមផ្លូវតុលាការដ៏រ៉ាំរ៉ៃ។

អ្នកជំនាញឯករាជ្យមានប្រសាសន៍ថា “ដូចអ្វីដែលបានសង្កត់ធ្ងន់នៅក្នុងសេចក្ដីសម្រេចប្រទេសកម្ពុជាគួរតែចាត់វិធានការជាបន្ទាន់ក្នុងការបង្កលក្ខណៈអំណោយផលដល់ប្រព័ន្ធមួយ ដែលសង្គមស៊ីវិលអាចចូលរួមដាយស្រួល និងលទ្ធិប្រជាធិបតេយ្យរឹងមាំ ព្រមទាំងការពារ និងធានានូវសេរីភាពបញ្ចេញមតិ សមាគម និងការប្រមូលផ្ដុំដោយសន្តិភាព”។ “យើងខ្ញុំគិតថាការផ្ដន្ទាទោសថ្មីៗនេះលើសកម្មជនអហិង្សាគឺជាការរំខាន និងមិនអំណោយផលទាល់តែសោះសម្រាប់ប្រទេសកម្ពុជាដែលប្រារព្ធខួប ៣០ឆ្នាំ បន្ទាប់ពីកម្ពុជាចុះកិច្ចព្រមព្រៀងសន្តិភាព”។

អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិសូមអំពាវនាវដល់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការបន្ទាន់ដើម្បីការពារលំហពលរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ តាមរយៈការអនុវត្តអនុសាសន៍នានាដែលប្រទេសកម្ពុជាបានទទួលយកនៅពេលត្រួតពិនិត្យជាសកលតាមកាលកំណត់កាលពីឆ្នាំ២០១៩។ ក្នុងចំណោមអនុសាសន៍ទាំងនោះ ក៏មានការសន្យាថានឹងបង្កើតលក្ខខណ្ឌល្អប្រសើរដែល “សង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្ស អាចបំពេញការងាររបស់ខ្លួនដោយសេរី ដោយគ្មានការជ្រៀតជ្រែក ឬរារាំង”។

ចប់